**សេចក្ដីសង្ខេបដោយប្រើភាសាសាមញ្ញអំពីគោលការណ៍ស្ដីពីជំនួយហិរញ្ញវត្ថុ**
**Fred Hutchinson Cancer Center**

កំណែបកប្រែអំពីសេចក្ដីសង្ខេប ទម្រង់ពាក្យសុំ និងគោលការណ៍ជំនួយហិរញ្ញវត្ថុនេះមាននៅ fredhutch.org/financial-assistance៖

- 财务援助政策简明概要, Simplified Chinese
- 재정 지원 정책 쉬운 요약, Korean
- Краткое изложение политики финансовой помощи доступным языком, Russian
- Resumen en lenguaje sencillo de la política de asistencia económica, Spanish
- Bản Tóm Tắt Bằng Ngôn Ngữ Đơn Giản Về Chính Sách Hỗ Trợ Tài Chính, Vietnamese
- Buod sa Simpleng Wika ng Patakaran sa Tulong Pinansyal,Tagalog
- ናይ ቋንቋ ጽማቕ ንጹር ፖሊሲ ፋይናንሳዊ ሓገዝ , Tigrinya
- Gunaanadka Macnaha Guud ee Siyaasadda Kaalmada Maaliyadda, Somali

Fred Hutchinson Cancer Center ប្ដេជ្ញាធានាថាអ្នកជំងឺរបស់យើងទទួលបានការថែទាំនៅក្នុងមន្ទីពេទ្យដោយមិនគិតពីលទ្ធភាពបង់ប្រាក់សម្រាប់ការថែទាំនោះឡើយ។ ការផ្ដល់ការថែទាំសុខភាពដល់អ្នកដែលមិនអាចបង់ប្រាក់បាន គឺជាផ្នែកមួយនៃបេសកកម្មរបស់យើង ហើយច្បាប់រដ្ឋតម្រូវឲ្យមន្ទីរពេទ្យផ្ដល់ការថែទាំដោយឥតគិតថ្លៃ និងបញ្ចុះតម្លៃដល់អ្នកជំងឺដែលមានសិទ្ធិទទួលបាន។ អ្នកអាចមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ការថែទាំដោយឥតគិតថ្លៃ និងបញ្ចុះតម្លៃ ដោយផ្អែកលើទំហំគ្រួសារ និងប្រាក់ចំណូល បើទោះបីជាអ្នកមានធានារ៉ាប់រងសុខភាពក៏ដោយ។

ប្រសិនបើអ្នកគិតថាអ្នកអាចមានបញ្ហាក្នុងការបង់ប្រាក់សម្រាប់ការថែទាំសុខភាពរបស់អ្នក សូមនិយាយជាមួយយើង។ ប្រសិនបើអាច យើងលើកទឹកចិត្តឲ្យអ្នកស្នើសុំជំនួយហិរញ្ញវត្ថុមុនពេលទទួលការព្យាបាលសុខភាព។

**តើអ្វីខ្លះត្រូវបានគ្របដណ្ដប់?** សម្រាប់សេវាកម្មនៅតាមមន្ទីពេទ្យសមរម្យនៅ Fred Hutchinson Cancer Center យើងផ្ដល់ការថែទាំដោយឥតគិតថ្លៃ និងជំនួយហិរញ្ញវត្ថុ/សប្បុរសធម៌ដល់អ្នកជំងឺដែលមានសិទ្ធិទទួលបាន ដោយផ្អែកលើកម្រិតតម្លៃប្រែប្រួលតម្រូវតាមអ្នកជំងឺដោយមានការបញ្ចុះតម្លៃចាប់ពី 50% រហូតដល់ 100%។ មិនមានអ្នកជំងឺណាម្នាក់ដែលមានសិទ្ធិទទួលបានជំនួយហិរញ្ញវត្ថុ/សប្បុរសធម៌ នឹងត្រូវបានគិតថ្លៃច្រើនជាងចំនួនទឹកប្រាក់ចេញវិក្កយបត្រជាទូទៅដល់អ្នកជំងឺដែលមានធានារ៉ាប់រងឡើយ។

**របៀបដាក់ពាក្យ៖** រាល់អ្នកជំងឺទាំងអស់អាចដាក់ពាក្យដើម្បីទទួលបានជំនួយហិរញ្ញវត្ថុ/ការថែទាំសប្បុរសធម៌តាមរយៈការដាក់ពាក្យសុំ និងការផ្ដល់សំណុំឯកសារគាំទ្របន្ថែម។ ប្រសិនបើអ្នកមានសំណួរ ត្រូវការជំនួយ ឬចង់ទទួលបានទម្រង់ពាក្យសុំ ឬព័ត៌មានបន្ថែម សូមទាក់ទងមកយើង៖

- នៅពេលអ្នកពិនិត្យចូល ឬពិនិត្យចេញពីមន្ទីពេទ្យ ឬគ្លីនិក។
- តាមទូរសព្ទ៖ (206) 606-6226 ឬទូរសព្ទឥតគិតថ្លៃតាមលេខ 1 (800) 304-1763
- នៅលើគេហទំព័ររបស់យើងតាម៖ fredhutch.org/financial-assistance
- ដោយផ្ទាល់៖ មកផ្នែកការប្រឹក្សាហិរញ្ញវត្ថុ (Financial Counseling) របស់យើងនៅ Lake Union Clinic របស់ Fred Hutchinson Cancer Center ដែលមានទីតាំងស្ថិតនៅ 825 Eastlake Ave. East, Seattle, Washington, 98109
- ដើម្បីទទួលបានឯកសារតាមរយៈសំបុត្រដោយឥតគិតថ្លៃ៖ អ៊ីមែល fincounsel@fredhutch.org ឬទូរសព្ទមកលេខ (206) 606-6226

**ជំនួយផ្សេងទៀត៖**
ជំនួយគ្របដណ្ដប់៖ អ្នកអាចនឹងមានសិទ្ធិទទួលបានកម្មវិធីរបស់រដ្ឋាភិបាល និងសហគមផ្សេងៗទៀត។ យើងអាចជួយអ្នកស្វែងយល់ថាតើកម្មវិធីទាំងនេះ (រួមទាំងអត្ថប្រយោជន៍ Medicaid/Apple Health និងកិច្ចការអតីតយុទ្ធជន) អាចជួយគ្របដណ្ដប់វិក្កយបត្រព្យាបាលរបស់អ្នកបានឬអត់។ យើងអាចជួយអ្នកដាក់ពាក្យសម្រាប់កម្មវិធីទាំងនេះបាន។

ការបញ្ចុះតម្លៃសម្រាប់អ្នកគ្មានធានារ៉ាប់រង៖ យើងផ្តល់ការបញ្ចុះតម្លៃសម្រាប់អ្នកជំងឺដែលមិនមានការគ្របដណ្តប់លើការធានារ៉ាប់រងសុខភាព។ សូមទាក់ទងមកយើងអំពីកម្មវិធីបញ្ចុះតម្លៃនេះ។

គម្រោងទូទាត់ប្រាក់៖ រាល់ប្រាក់នៅខ្វះមិនទាន់បង់ណាមួយដែលបានជំពាក់ដោយអ្នក គឺដល់កាលកំណត់សងក្នុងរយៈពេល 30 ថ្ងៃ។ ប្រាក់នៅខ្វះមិនទាន់បង់អាចបង់បានដោយវិធីសាស្ត្រណាមួយដូចតទៅ៖ កាតឥណទាន គម្រោងទូទាត់ប្រាក់ សាច់ប្រាក់ សែក ឬការបង់ប្រាក់វិក្កយបត្រតាមអនឡាញ។ ប្រសិនបើអ្នកត្រូវការគម្រោងទូទាត់ប្រាក់ សូមទូរសព្ទទៅលេខដែលមាននៅលើរបាយការណ៍វិក្កយបត្ររបស់អ្នក។

សូមអរគុណសម្រាប់ការជឿទុកចិត្តមកលើយើងខ្ញុំសម្រាប់ការថែទាំរបស់អ្នក។